# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC
# Meet the Business Owner Who Received a Loan Guaranteed by CGCC

### លោក ឈុន ធំ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ឈុន ធំ | Mr. Chhun Thom, Founder of Chhun Thom Rice Miller

KH វិស័យកសិកម្មគឺជាវិស័យស្នូលមួយក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ។ ក្នុងនោះ ទីផ្សារស្រូវអង្ករដើរតួយ៉ាងសំខាន់ក្នុងការលើកតម្កើងវិស័យកសិកម្ម។ រោងម៉ាស៊ីនផលិតស្រូវអង្ករ ឈុន ធំ ត្រូវបានចាប់បដិសន្ធិកិច្ច ក្នុងឆ្នាំ១៩៩៧ ដែលដំបូងឡើយជាមុខជំនួញបែបលក្ខណៈគ្រួសារមួយ។ បន្ទាប់ពីចាប់ផ្តើមដំណើរការអស់រយៈពេលជាច្រើនឆ្នាំមក អតិថិជនបានស្គាល់ពីម៉ាកយីហោ និងចាប់ផ្តើមផ្តល់ការជឿទុកចិត្តលើផលិតផលរបស់ពួកយើង។ ខ្ញុំបាទបានមើលឃើញពីឱកាស ក្នុងការពង្រីកអាជីវកម្មនេះឱ្យកាន់តែធំជាពិសេសលើបច្ចេកវិទ្យាដូចជាការទិញបន្ថែមនូវម៉ាស៊ីនកិនស្រូវ និងពង្រីកទីតាំងកិនស្រូវបន្ថែម។

ខ្ញុំបាទបានទទួលការប្រឹក្សាជាមួយបុគ្គលិកធនាគារ ABA អំពីការធានាឥណទានលើកម្ចីអាជីវកម្មរបស់ CGCC ដែលអាចផ្តល់ការធានាលើកម្ចីរបស់ខ្ញុំ ទោះបីគ្មានទ្រព្យធានា។ ដោយសារការធានាឥណទានពី CGCC ទៅលើកម្ចីដែលទទួលបានពីធនាគារ ABA ខ្ញុំអាចទទួលបានទុនបន្ថែម ក្នុងការពង្រីកអាជីវកម្មរោងម៉ាស៊ីនកិនស្រូវរបស់ខ្ញុំបាទ ដូចជាការបន្ថែមគ្រឿងបរិក្ខារ មានដូចជាម៉ាស៊ីនកិនស្រូវ និងពង្រីកទីផ្សារឱ្យកាន់តែធំទូលាយជាងមុន ព្រមទាំងសង្វាក់ផលិតកម្មឱ្យកាន់តែរលូនទៅមុខជាដើម។

ខ្ញុំយល់ថា ការធានាឥណទានរបស់ CGCC ពិតជាអាចគាំទ្រដល់អាជីវកម្មរបស់ខ្ញុំក៏ដូចជាសហគ្រាសខ្នាតតូច និងមធ្យមផ្សេងទៀត ដែលមានសក្តានុពល ប៉ុន្តែខ្វះទ្រព្យធានា ឱ្យទទួលបានទុនបន្ថែមចាំបាច់ពីធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់ការពង្រីកអាជីវកម្ម៕





EN Agriculture is a key sector in supporting the national economic growth. Rice market also plays an important role in promoting agriculture. Chhun Thom Rice Mill was established in 1997, initially as a family business. After years of operation, customers know the brand and begin to trust our products. I have seen opportunities to expand this business, especially on technologies such as the purchase of additional rice mills and the expansion of the location of the mill.

I was introduced by ABA Bank staff about the loan guaranteed by CGCC which can provide me additional capital even without collateral. Thanks to the credit guarantee from CGCC, I was able to get more capital to expand my rice mill business.

I strongly believe that the CGCC's credit guarantee really support my business, as well as other potential SMEs that lack collateral to get necessary capital from banks or microfinance institutions for their business expansion.

